# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងសន្និបាតប្រចាំឆ្នាំលើកទី ៧៥ របស់ UN-ESCAP

## ការផ្តល់សិទ្ធិអំណាចប្រជាជន និង ការធានានូវបរិយាប័ន្ន និង សមភាព

**ទីក្រុងបាងកក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៩**

- ***ឯកឧត្តម ដាមឌីន ឋុសបាតា*** *(Damdin Tsogtbaatar)* ***ប្រធានសន្និបាត***
- ***ឯកឧត្តម បារ៉ុន ឌីវ៉ាវេស៊ី វ៉ាហ្គា*** *(Baron Divavesi Waqa)* ***ប្រធានាធិបតីនៃប្រទេសណូរូ***
- ***លោកជំទាវ អារមីដា សាល់ស៊ីយ៉ា អាលីសចាបាណា*** *(Armida Salsiah Alisjahbana)* ***អគ្គលេខាធិការរង អង្គការសហប្រជាជាតិ និង ជាប្រធាន*** *ESCAP;*
- ***លោកជំទាវ, ឯកឧត្តម, លោកស្រី, អស់លោក !***

ថ្ងៃនេះ, ខ្ញុំមានសេចក្តីរីករាយជាអនេក ដោយបានមកចូលរួមក្នុងសន្និបាតប្រចាំឆ្នាំលើកទី ៧៥ របស់គណៈកម្មការសេដ្ឋកិច្ច និង សង្គមកិច្ច សម្រាប់អាស៊ី និង ប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ (UN-ESCAP) ក្រោមប្រធានបទ : **ការផ្តល់សិទ្ធិអំណាចជូនប្រជាជន និង ការធានានូវបរិយាប័ន្ន និងសមភាព** ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមថ្លែងអំណរគុណ និង វាយតម្លៃខ្ពស់ ចំពោះ UN-ESCAP ដែលបានរៀបចំ និង អញ្ជើញខ្ញុំ ចូលរួមក្នុងព្រឹត្តិការណ៍ដ៏សំខាន់មួយនេះ ។

របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព គឺជាការអំពាវនាវឱ្យមានសកម្មភាពក្នុងការឆ្លើយតបទៅនឹងគោលដៅ : **«គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល»** ។ ប្រធានបទនៃវេទិកាពិភាក្សានយោបាយកម្រិតខ្ពស់ឆ្នាំ ២០១៩ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព (SDGs) និង ប្រធានបទនៃសន្និបាតឆ្នាំនេះ ស្តែងចេញនូវសុឆន្ទៈរបស់សហគមន៍ពិភពលោក ក្នុងការតម្រង់ទិសសង្គមដែលមានការបែងចែកសំដៅជំរុញឱ្យសង្គមទាំងនោះ ផ្តល់នូវសិទ្ធិអំណាច, បរិយាប័ន្ន និង ការផ្តល់នូវឱកាសស្មើៗគ្នាដល់មនុស្សគ្រប់រូប ។ ខ្ញុំមានការជឿជាក់ខ្ពស់ថា UN-ESCAP ក្រោមការដឹកនាំដ៏មោះមុត និង ប្រកបដោយថាមវន្តរបស់លោកជំទាវ **អារមីដា សាល់ស៊ីយ៉ា អាលីសចាបាណា** (Armida Salsiah Alisjahbana) អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ និង ជាប្រធាន UN-ESCAP នឹងទទួលបានជោគជ័យយ៉ាងពិតប្រាកដលើគោលដៅនេះ ។

ច្បាស់ណាស់ថា, ជាទូទៅ, ភាពខុសគ្នា ឬ ការបែងចែករវាងក្រុមសង្គមផ្សេងៗ តែងតែកើតមាន នៅក្នុងគ្រប់សង្គមជាតិ ។ ដោយឡែក, ចំពោះប្រជាជនកម្ពុជា, ទោះបីទទួលបានការរីកចម្រើនក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះក្តី, ក៏នៅមានស្រទាប់ប្រជាជន ឬ សហគមន៍មួយចំនួន មិនទាន់ទទួលបាននូវសិទ្ធិអំណាចសមរម្យ, នៅងាយទទួលរងគ្រោះ និង នៅមិនទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ផងដែរ ។ តើយើងគួរធ្វើបែបណា ទើបប្រជាជនយើងក្លាយជាភ្នាក់ងារក្នុងការផ្លាស់ប្តូរ និង ក្នុងការកំណត់ជោគវាសនារបស់ខ្លួន ហើយទទួលបានសិទ្ធិអំណាចសមរម្យ ? តើធ្វើបែបណាទើបអាចជំនះលើឧបសគ្គនានា ដើម្បីឆ្ពោះទៅសម្រេចសមភាពសង្គម សមស្របតាមបំណងប្រាថ្នារបស់យើងបាន ? ខ្ញុំមានជំនឿថា វិធីសាស្ត្រមួយដែលយើងអាចអនុវត្តបាន ដើម្បីឈានទៅសម្រេចបាននូវគោលដៅនេះ គឺការធ្វើបរិយាប័ន្នកម្ម ។ ការធ្វើបរិយា-ប័ន្នកម្ម អាចសម្រេចទៅបាន តាមរយៈការផ្តល់សិទ្ធិអំណាចដល់ប្រជាជន ដោយចាប់ផ្តើមពីថ្នាក់មូលដ្ឋានដែលជាការអនុញ្ញាតឱ្យពួកគាត់អាចបង្ហាញពីតម្រូវការរបស់ខ្លួន សម្រាប់ការផ្លាស់ប្តូរទៅរកសង្គមមួយដែលកាន់តែមានសមធម៌ ។ ជាលទ្ធផលត្រឡប់មកវិញ, សង្គមមួយដែលកាន់តែមានសមធម៌ ក៏នឹងក្លាយជាមូល-ដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ការផ្តល់សិទ្ធិអំណាចកាន់តែពេញលេញ និង ការបង្កើនបរិយាប័ន្ន នាពេលអនាគតផងដែរ ។

ក្នុងន័យនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់ UN-ESCAP ក្នុងការរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក, ជាពិសេស តាមរយៈការគាំទ្រដល់ការអនុវត្ត SDGs ដែលចាត់ទុកបរិយាប័ន្នជាចំណុចស្នូល និង ជាគោលដៅចម្បង ។ តួនាទីនេះ រឹតតែមានសារៈសំខាន់ថែមទៀតសម្រាប់តំបន់យើង ក្នុងកាលៈទេសៈបច្ចុប្បន្ន ដែលពិភពលោក និង សកលភាវូបនីយកម្មកំពុងត្រូវ-បានគម្រាមកំហែងដោយចរន្តគាំពារនិយម, សង្គ្រាមពាណិជ្ជកម្មរវាងមហាអំណាចធំៗ និង វិបត្តិភូមិសាស្ត្រនយោបាយ, ក៏ដូចជាក្នុងពេលអនាគត ដែលសកលលោកត្រូវប្រឈមដោះស្រាយនូវបញ្ហាប្រែប្រួលរចនា-សម្ព័ន្ធធំៗ ជាអាទិ៍ បញ្ហាប្រជាសាស្ត្រនៃមនុស្សចាស់ និង មនុស្សក្មេង, បញ្ហាហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់, សន្តិ-សុខថាមពល, បញ្ហាទឹក និង បរិស្ថាន ព្រមទាំងការរីកចម្រើននៃបច្ចេកវិទ្យា ដើម្បីកសាងអនាគតតំបន់មួយដ៏រុងរឿង ស្របតាមនិន្នាការនៃបដិវត្តន៍ឧស្សាហកម្មទី ៤ ឬ សេដ្ឋកិច្ចឌីជីថល ។

## *លោកជំទាវ, ឯកឧត្តម, លោកស្រី, អស់លោក ជាទីមេត្រី !*

នាឱកាសនេះ, អនុញ្ញាតឱ្យខ្ញុំសូមចែករំលែកជូនអស់លោកអ្នកទាំងអស់គ្នាជ្រាប អំពីជោគជ័យរបស់កម្ពុជា ក្នុងការបញ្ចប់សង្គ្រាមស៊ីវិល និង ការធ្វើបរិយាប័ន្នកម្ម តាមរយៈ **គោលនយោបាយឈ្នះ-ឈ្នះ** សម្រាប់ប្រជាជនកម្ពុជា គ្រប់ស្រទាប់វណ្ណៈ និង គ្រប់និន្នាការនយោបាយ ។

ព្រះរាជាណាចក្រកម្ពុជា ទទួលបានសុខសន្តិភាព និង ការបង្រួបបង្រួមជាតិសម្រាប់ប្រទេសទាំងមូលជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន នៅចុងឆ្នាំ ១៩៩៨ ។ សង្គ្រាមដែលបានអូសបន្លាយរយៈពេលជាង ៣០

ឆ្នាំ ត្រូវបានបញ្ចប់ទាំងស្រុង នៅពេលកងទ័ពខ្មែរក្រហមបានចុះចូល និង ចូលរួមជាមួយរាជរដ្ឋាភិបាលស្រប ច្បាប់របស់កម្ពុជា ។ នេះ គឺជាលទ្ធផលទទួលបានពី **គោលនយោបាយឈ្នះ-ឈ្នះ** ដែលយើងបានដាក់ចេញមកដោយខ្លួនឯង ដោយគ្មានការបង្គាប់បញ្ជា ឬ ជំនួយពីខាងក្រៅ ។

ខ្ញុំសូមជម្រាបជូនថា **គោលនយោបាយឈ្នះ-ឈ្នះ** មានរួមបញ្ចូលសមាសធាតុជាមូលដ្ឋានចំនួន ៣ សំខាន់ៗ គឺ : **ទី១–** ការធានាថា បុគ្គលគ្រប់រូបអាចបន្តរស់រានមានជីវិត, **ទី២–** ការធានាថា បុគ្គលគ្រប់រូបមានការងារ និង មុខរបរចិញ្ចឹមជីវិត, **ទី៣–** ការធានាការពារនូវទ្រព្យសម្បត្តិរបស់ពួកគេទាំងអស់គ្នា ។ ជាលទ្ធ-ផលនៃ **គោលនយោបាយឈ្នះ-ឈ្នះ** នេះ, សង្គ្រាម និង ជម្លោះប្រដាប់អាវុធ ត្រូវបានបញ្ចប់ទាំងស្រុង ហើយកម្ពុជាអាចដោះស្រាយបាននូវបញ្ហាគ្រប់យ៉ាង តាមរយៈការកសាងទំនុកចិត្តរវាងខ្មែរ និង ខ្មែរ ដែលជាប្រការនាំមកនូវសន្តិភាពដ៏រឹងមាំ ហើយចាក់ឫសកាន់តែជ្រៅក្នុងសង្គមជាតិ ក្នុងរយៈពេលជាង ២០ ឆ្នាំចុងក្រោយនេះ ។

សន្តិភាព គឺជាបុរេលក្ខខណ្ឌដ៏ចម្បង និង សំខាន់បំផុត សម្រាប់កសាងខឿនសេដ្ឋកិច្ច និង អភិវឌ្ឍសង្គមជាតិ ។ លើមូលដ្ឋាននេះ, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ជាមធ្យមក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំ, ក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយ ហើយបានប្រែក្លាយខ្លួនជាប្រទេសមួយក្នុងចំណោមប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតក្នុងពិភពលោក ព្រមទាំងបានឆ្លងកាត់ពីឋានៈប្រទេសចំណូលទាប មកជាប្រទេសចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ ២០១៥ កន្លងទៅ ។ អត្រាភាពក្រីក្រនៅកម្ពុជា បានបន្តធ្លាក់ចុះជាលំដាប់ពីជាង ៥៣% ក្នុងឆ្នាំ ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ ២០១៤ ហើយត្រូវបានប៉ាន់ស្មានថា ស្ថិតនៅក្នុងរង្វង់ ១០% នាបច្ចុប្បន្ន ។ វិស័យសុខាភិបាល និង អប់រំ ក៏សម្រេចបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់ ទោះបីនៅមានសេសសល់បញ្ហាប្រឈមមួយចំនួន ដែលរាជរដ្ឋាភិបាលត្រូវបន្តដោះស្រាយក៏ដោយ ។ ជាមួយនឹងសមិទ្ធ-ផលដ៏ធំធេងនេះ, កម្ពុជាមានមហិច្ឆិតាក្នុងការក្ដាប់យកមកវិញនូវមោទនភាពជាតិ តាមរយៈការប្រែក្លាយខ្លួនទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ។

ជាមួយគ្នានេះផងដែរ ខ្ញុំក៏សូមយកឱកាសនេះគូសរំលេចអំពីកិច្ចប្រឹងប្រែង និង ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឈានទៅសម្រេចបាននូវគោលដៅ : **«គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល»** តាមរយៈការជំរុញអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍ជាគន្លឹះ ចំនួន ៣ គឺ÷

**ទី១–** ការដាក់ចេញនូវ **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រក្នុងការធានាឱ្យមានសុវត្ថិភាពប្រាក់ចំណូល និង កាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋ-កិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងបង្កើនសុខុមាលភាពរបស់ប្រជាជន និង ពង្រឹងសាមគ្គីភាពក្នុងសង្គម ។

**ទី២–** ការផ្ដល់សេវាថែទាំសុខភាព ដែលមានគុណភាព និង មានតម្លៃសមរម្យ តាមរយៈមូលនិធិសម-ធម៌សុខាភិបាល ដែលបានផ្ដល់សេវាថែទាំសុខភាពដោយឥតគិតថ្លៃដល់ប្រជាជនក្រីក្រ ព្រមទាំងការផ្ដល់នូវ

ជំនួយឧបត្ថម្ភជាសាច់ប្រាក់ដល់ស្ត្រីសម្រាលកូន ក៏ដូចជាដល់ស្ត្រីមានផ្ទៃពោះ និង កុមារអាយុក្រោម ២ ឆ្នាំ នៃគ្រួសារក្រីក្រ ។

**ទី៣-** ការដាក់ចេញនូវគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ដែលសំដៅគាំទ្រ និងដោះស្រាយបញ្ហារបស់មនុស្សវ័យចាស់ ដោយយកចិត្តទុកដាក់លើការប្រែប្រួលនៃកត្តាប្រជាសាស្ត្រ ជាមួយនឹងចក្ខុវិស័យនៃការធានាថា មនុស្សវ័យចាស់អាចចូលរួមដោយសេរី និង មានសេចក្តីថ្លៃថ្នូរ នៅក្នុងគ្រួសារ, សហគមន៍, សកម្មភាពសេដ្ឋកិច្ច, សកម្មភាពសាសនា និង សកម្មភាពនយោបាយ តាមបំណងប្រាថ្នារបស់ពួកគាត់ ហើយប្រជាជនវ័យក្មេង ក៏ត្រូវតែទទួលបានចំណេះដឹង និង ជំនាញ ដែលអាចអនុញ្ញាតឱ្យពួកគេរស់នៅប្រកបដោយផលិតភាព, សុខភាពល្អ, មានភាពសកម្ម និង មានសេចក្តីថ្លៃថ្នូរ នៅពេលពួកគេឈានដល់វ័យចំណាស់។

***លោកជំទាវ, ឯកឧត្តម, លោកស្រី, អស់លោក ជាទីមេត្រី !***

បទពិសោធន៍របស់កម្ពុជា បានបញ្ជាក់ច្បាស់ថា សន្តិភាព និង ស្ថិរភាព គឺជាមូលដ្ឋានគ្រឹះមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍, ហើយបញ្ច្រាសមកវិញ ការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្ន និង សមធម៌ គឺជាលក្ខខណ្ឌដ៏ចាំបាច់ សម្រាប់ពង្រឹង និង ធានានូវសុខសន្តិភាព និង ស្ថិរភាពសង្គម ។ លើមូលដ្ឋាននៃបទពិសោធន៍នេះ, ប្រជាជាតិកម្ពុជាទាំងមូល ផ្តល់តម្លៃខ្ពស់បំផុតចំពោះការខិតខំបន្តថែរក្សាសន្តិភាព និង ស្ថិរភាព ព្រមទាំងការជំរុញកិច្ចអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ដែលបច្ចុប្បន្ននេះ កំពុងតែហុចផ្លែផ្កាយ៉ាងពិតប្រាកដ ជាប្រយោជន៍ជូនដល់ពលរដ្ឋកម្ពុជា នៅគ្រប់ច្រកល្ហកក្នុងផ្ទៃប្រទេស ។

មុននឹងបញ្ចប់, ខ្ញុំសូមសម្តែងជាថ្មីម្តងទៀត នូវការវាយតម្លៃខ្ពស់ជូនចំពោះអង្គការសហប្រជាជាតិ និង ដៃគូអភិវឌ្ឍន៍នានា ដែលបានបន្តកិច្ចសហការ និង គាំទ្រដល់ប្រទេស និង ប្រជាជនកម្ពុជា ក្នុងពេលកន្លងមក ហើយរំពឹងយ៉ាងមុតមាំចំពោះសុឆន្ទៈនៃការពង្រឹង និង លើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ ឱ្យកាន់តែសកម្មខ្លាំងឡើងថែមទៀត ដើម្បីគោលដៅរួមរបស់យើងទាំងអស់គ្នា គឺ : **ការកសាងពិភពលោកមួយ ដែលគ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល** ។

ជាចុងបញ្ចប់, ខ្ញុំសូមជូនពរឱ្យសន្និបាតប្រចាំឆ្នាំលើកទី ៧៥ នេះ ទទួលបានផ្លែផ្កាជាទីមោទនៈ និង សូមឱ្យអ្នកចូលរួម និង ភ្ញៀវកិត្តិយសគ្រប់រូបនៅក្នុងអង្គសន្និបាត បានសមប្រកបតែនឹងសន្តិភាព, ភាពសុខដុមរមនា, សុខភាព, វិបុលភាព និង សុភមង្គល កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរគុណ !***